**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៥២៩ សហវ [illegible]

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារចម្រុះ រវាង
## អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ បក.ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **កែន សម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សហប្រធាន |
| ២- | លោក | **នួន ច័ន្ទរិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សហប្រធាន |
| ៣- | លោក | **ឡើម រដ្ឋា** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៤- | លោក | **អេង រតនា** | ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៥- | លោក | **រ័ត្ន មុនី** | ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៦- | លោម | **ស្រ៊ុន អង្គរ៉ែន** | ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៧- | លោក | **លីម ដឺលុច** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៨- | លោក | **សែ សុឃុន** | ប្រធាននាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៩- | លោក | **សុខ សុចិន្ដា** | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១០- | លោក | **ប៊ូ សណ្ដាប់** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១១- | លោក | **កែវ ប៉ង់តា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |

| | | | |
|---|---|---|---|
| ១២-បណ្ឌិត | **សង់ ស៊ីណាវិទ្យ** | អនុប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៣-លោក | **ស្រេង សំណាង** | អនុប្រធាននាយកដ្ឋានច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៤-លោក | **សង់ សិទ្ធានិត្យ** | អនុប្រធាននាយកដ្ឋានរបបគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៥-លោក | **ជុំ សុលីវណ្ណា** | ប្រធានការិយាល័យកិច្ចការទូទៅ នៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៦- លោក | **កែ ឈុំបញ្ញា** | ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៧-លោក | **ញៀត សម្បត្តិ** | ប្រធានការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៨-លោក | **ជួប ច័ន្ទសោភា** | ប្រធានការិយាល័យស្ថិតិ និងប្រព័ន្ធព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៩- លោក | **សែម ម៉េង** | ប្រធានការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ២០-លោក | **គង់ សុខផល្លាគុណ** | ជំនួយការនាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |

**ប្រការ ២.-**

ក្រុមការងារចម្រុះនេះ មានភារកិច្ចដូចតទៅ÷

១- សហការ និងសម្របសម្រួលដល់ការផ្តល់ជូនគ្នាទៅវិញទៅមកនូវព័ត៌មាន និងទិន្នន័យនានា ដែលអាចបម្រើឱ្យការសិក្សា វិភាគ និងដើម្បីលើកវិធានពង្រឹងការគ្រប់គ្រង និងបង្កើនការប្រមូលចំណូលពន្ធដារ និងចំណូលពន្ធគយ

២- សិក្សាពិនិត្យឡើងវិញ និងផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកិច្ចការដែលពាក់ព័ន្ធរបស់អគ្គនាយកដ្ឋានទាំងពីរ ចំពោះការកែទម្រង់គោលនយោបាយពន្ធដារ និងពន្ធគយ

៣- ពង្រឹងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើគេចពន្ធ

៤- ពិនិត្យ និងដោះស្រាយរាល់ករណីកើតឡើងទាំងឡាយដែលមានពាក់ព័ន្ធរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា



ꙋ

៥- បំពេញការងារផ្សេងទៀតតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៣.-**

១- សហប្រធាននៃក្រុមការងារនេះ ត្រូវដឹកនាំការប្រជុំយ៉ាងតិច ១ដង ក្នុងមួយខែ។ ក្នុងករណីសហប្រធានអវត្តមានដោយប្រការណាមួយ សហប្រធាននោះ អាចចាត់តាំងតំណាងមួយរូបក្នុងក្រុមការងារ ដើម្បីដឹកនាំការប្រជុំនោះ

២- សហប្រធានត្រូវធ្វើការបូកសរុប និងធ្វើរបាយការណ៍អំពីលទ្ធផលនៃរាល់ការប្រជុំ ជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣- ក្រុមការងារនេះអាចប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋានពន្ធដារ ឬអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សម្រាប់បំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ ៤.-**

ប្រកាសលេខ ៦៩៣ សហវ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៣កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ